## គណៈកម្មាធិការនាយក
**BOARD OF DIRECTORS**

1. លោក **ធន សារាយ**
**Mr. THUN Saray**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

2. លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

3. លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និងជានាយក **CCPCR**

4. អ្នកស្រី **ស៊ុន ចាន់សែន**
**Mrs. SUN Chansen** សមាជិកា
និងជាប្រធាន **KYA**

5. លោក **យង់ គិមអេង**
**Mr. YONG Kim Eng** សមាជិក
និងជានាយក **PDP-Center**

6. លោក **មុំ សារិន**
**Mr. MOM Sarin** សមាជិកា
និងជានាយក **HRCDO**

7. អ្នកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet** សមាជិកា
និងជាសហនាយិកា **WMC**

8. កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
សមាជិកា
និងជានាយិកា **CWCC**

9. លោក **គីម សុវណ្ណ**
**Mr. KIM Sovann** សមាជិក
និងជានាយក **VIGILANCE**

10. នាយក **LAC (NA)**

11. នាយក **KKKHRO (NA)**

12. អ្នកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep** សមាជិកា
ជាឥស្សរជន Dignitary

13. លោក **សឹន សែត**
**Mr. SEN Set** សមាជិក
ជាឥស្សរជន

"ពិន្ទុ៣ សំរាប់ការបានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល (៤១%-៦០%)" "ពិន្ទុ៤ សំរាប់ការបានធ្វើច្រើន (៦១%-៨០%)" និង "ពិន្ទុ៥ សំរាប់ ការបានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង (៨១%-១០០%)" ។

ជាលទ្ធផល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុទៅលើការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់កាលពីឆ្នាំ២០០៩ ដូចខាងក្រោម៖

| **លទ្ធផលនៃការវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការសម្រេចបាន របស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអធិភាពទាំងដប់នៅក្នុងខេត្តប៉ៃលិន** |
|---|
| ១) សុំរកទីផ្សារសេរីសំរាប់លក់ផលិតផលកសិកម្មដូចជា ស្រូវ ដំឡូងមី សណ្តែកបាយ ពោត,.,.,យ៉ាងហោចណាស់មួយគីឡូក្រាមជាមធ្យម អោយបាន ២៥% នៃតម្លៃសាំង ១ លីត្រ នៅខេត្តប៉ៃលិន ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០០៩ នេះតទៅ ។<br>ពិន្ទុ **១ (៤%)** ពិន្ទុ **២ (១៤%)** ពិន្ទុ **៣ (៥១%)** ពិន្ទុ **៤ (២៨%)** ពិន្ទុ **៥(២%)** |
| ២) សុំអោយមានការនាំចេញ ចូល កសិផល និងយកពន្ធតិចជាងតម្លៃបច្ចុប្បន្ន [ខែកក្កដា ឆ្នាំ ២០០៩] ប្រហែល ៥០% នៅក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ ២០០៩ ។<br>ពិន្ទុ **១ (៦%)** ពិន្ទុ **២ (៦១%)** ពិន្ទុ **៣ (២៤%)** ពិន្ទុ **៤ (៥%)** ពិន្ទុ **៥(៥%)** |
| ៣) ត្រូវអោយមានការត្រួតពិនិត្យ និងបណ្តុះបណ្តាលតាមបច្ចេកទេសដោយមន្ទីរកសិកម្មខេត្ត ។ ពូជដំណាំកសិកម្មដែលនាំចូលអោយមាន តម្លៃទាបជាងតម្លៃបច្ចុប្បន្ន [ខែកក្កដា ឆ្នាំ ២០០៩] ដល់កសិករក្នុងខេត្តប៉ៃលិនចាប់ពីឆ្នាំ ២០១០ នេះតទៅ ។<br>ពិន្ទុ **១ (១៣%)** ពិន្ទុ **២ (៥៣%)** ពិន្ទុ **៣ (២៤%)** ពិន្ទុ **៤ (៨%)** ពិន្ទុ **៥(២%)** |
| ៤) សុំអោយមានប្រឡាយទឹកនៅឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅដែលប្រឡាយមានប្រវែង ៣០គម ទំហំ មាត់លើ ៥ ម៉ែត្រ ពិចំនុចភូមិទំនប់ ដល់ទីប្រជុំជនឃុំស្ទឹងត្រង់ចាប់ពីឆ្នាំ ២០១០ ដល់ ២០១២ ។<br>ពិន្ទុ **១ (៤១%)** ពិន្ទុ **២ (៤១%)** ពិន្ទុ **៣ (១៤%)** ពិន្ទុ **៤ (១%)** ពិន្ទុ **៥(២%)** |
| ៥) សុំផ្លូវក្រួសក្រហម និងស្ពានចំនួន 0៤ ខ្សែ ចាប់ពីឆ្នាំ ២០១០ ដល់ ២០១៥ ។ ទី ១ នៅក្នុងសង្កាត់អូរតាវៅ ពីភូមិប៉ាងរលឹមដល់ភូមិក្រចាប់លើ ប្រហែល ១២ គម ។ ទី ២ ក្នុងឃុំអូរអណ្តូងចាប់ពី ភូមិថ្នល់កែង ដល់ភូមិកូនដំរី ឃុំស្ទឹងត្រង់ មានប្រវែងប្រហែល ១៨គម ។ ទី ៣ ពីភូមិភ្នំកុយ ដល់ភូមិស្រែអន្ទាក់ ក្នុងឃុំសាលាក្រៅ ប្រវែង ៨គម ។ និងទី ៤ សុំស្ពានមួយកន្លែងនៅភូមិបតាំងស៊ូ សង្កាត់បយ៉ាខា ។<br>ពិន្ទុ **១ (៩%)** ពិន្ទុ **២ (២៦%)** ពិន្ទុ **៣ (៣៣%)** ពិន្ទុ **៤ (២៧%)** ពិន្ទុ **៥(៤%)** |
| ៦) សុំតម្លើងប្រាក់ឧបត្ថម្ភចាប់ពីមេភូមិ មេឃុំ អោយបាន ១០០% នៃប្រាក់ឧបត្ថម្ភបច្ចុប្បន្ន [ខែកក្កដា ឆ្នាំ ២០០៩ ] ។ សំរាប់មន្ត្រីរាជការគ្រប់ស្ថាប័នក្នុងខេត្តប៉ៃលិន សុំតម្លើងប្រាក់ខែប្រចាំខែអោយបាន ៤០% ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ ២០១០ តទៅ ។<br>ពិន្ទុ **១ (៥១%)** ពិន្ទុ **២ (៣៩%)** ពិន្ទុ **៣ (៤%)** ពិន្ទុ **៤ (៤%)** ពិន្ទុ **៥(១%)** |
| ៧) សុំអោយមានឥណទានដែលមានការប្រាក់ទាប (១%ក្នុង១ខែ) សំរាប់ប្រជាពលរដ្ឋដែលជាកសិករខ្ចីនៅក្នុង ខេត្តប៉ៃលិន ពីឆ្នាំ ២០១០ ដល់ ២០១៥ ។<br>ពិន្ទុ **១ (៣៩%)** ពិន្ទុ **២ (៤៥%)** ពិន្ទុ **៣ (១៤%)** ពិន្ទុ **៤ (១%)** ពិន្ទុ **៥(១%)** |

៨) សុំអោយមានការព្យាបាលជំងឺដោយពុំយកកំរៃសេវាព្យាបាលក្នុងមន្ទីរពេទ្យបង្អែក ក្នុងខេត្តប៉ៃលិនឬបញ្ចុះតំលៃ ៥០%ពីតម្លៃបច្ចុប្បន្ន [ខែកក្កដា ឆ្នាំ ២០០៩] អោយបាននៅក្នុងឆ្នាំ ២០១០ ។

ពិន្ទុ **១ (១២%)** ពិន្ទុ **២ (៤០%)** ពិន្ទុ **៣ (៣៨%)** ពិន្ទុ **៤ (៩%)** ពិន្ទុ **៥(១%)**

៩) សុំអោយបង្កើតច្បាប់ប្រឆាំងអំពើពុករលួយអោយបាននៅចុងឆ្នាំ ២០០៩ ខាងមុខនេះតទៅ ។

ពិន្ទុ **១ (៥%)** ពិន្ទុ **២ (២៣%)** ពិន្ទុ **៣ (៣៩%)** ពិន្ទុ **៤ (២១%)** ពិន្ទុ **៥(១៣%)**

១០) សុំតម្លើងប្រាក់បៀវត្សរ៍គ្រូបង្រៀនយ៉ាងតិច ៤០ម៉ឺនរៀលក្នុងមួយខែ បើកអោយបានទៀងទាត់រៀងរាល់ខែ នៅក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ ២០១០ ។

ពិន្ទុ **១ (៣%)** ពិន្ទុ **២ (៧%)** ពិន្ទុ **៣ (៤១%)** ពិន្ទុ **៤ (៣៦%)** ពិន្ទុ **៥(១៣%)**

១១) **ចំនុចរួមៈ តើអ្នកពេញចិត្តការអនុវត្តរបស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍ទាំង១០ កម្រិតណា?**

□ ១) មិនពេញចិត្តទាល់តែសោះ, □២) ពេញចិត្តតិចតួច, □ ៣) ពេញចិត្តគួរសម, □៤) ពេញចិត្តច្រើន, □៥) ពេញចិត្តទាំងស្រុង

ពិន្ទុ **(៤%)** ពិន្ទុ **(៦%)** ពិន្ទុ **(២៧%)** ពិន្ទុ **(៤៨%)** ពិន្ទុ **(១៥%)**

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយម្ចាស់ឆ្នោតក្នុងវេទិកាម្ចាស់ឆ្នោតនៅខេត្តប៉ៃលិននៅថ្ងៃទី ២៤ មិថុនា ដែលរៀបចំដោយគណៈកម្មាធិការ**ខុមហ្វ្រែល** ដោយមានកិច្ចសហការជាមួយសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD) និង អង្គការឃៃរកម្ពុជា ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទងៈ*

- លោក **សុខ ពិន្ទុរឿ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទៈ ០៨៩ ៥២៥ ៤៤៦